ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ ១៩៣ ស ហ វ អពដ.ប្រក

# ប្រកាស

## ស្តីពី

## វិធាន និងនីតិវិធី

## ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយទៅជា អគ្គនាយកដ្ឋានគយកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋាន រតនាគារជាតិ ស្ថិតក្រោមគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៣០ សហវ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

ប្រការ១. បំណុលសារពើពន្ធ គឺជាប្រាក់អាករគ្រប់ប្រភេទ ដែលមិនបានបង់នៅពេលដល់កំណត់ត្រូវបង់ ។ បំណុលពន្ធរួមមានប្រាក់ពន្ធអាករ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលទាក់ទិន ។ ផ្អែកតាមកថាខ័ណ្ឌ ៤ នៃមាត្រា ១០៧ នៃច្បាប់សារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិប្រមូលបំណុលពន្ធ រហូតដល់ថ្ងៃដែលបំណុលពន្ធត្រូវបានចាត់ទុកជា ប្រាក់ពន្ធមិនអាចប្រមូលបាន ។

បំណុលដែលត្រូវបានចាត់ទុកជា ប្រាក់ពន្ធមិនអាចប្រមូលបាន ត្រូវមានលក្ខណៈ វិនិច្ឆ័យ ទាំងបីដូចខាងក្រោមៈ

១- អ្នកជាប់ពន្ធបាត់ខ្លួនយ៉ាងតិច ៥ ឆ្នាំ មកហើយ ឬទទួលរងគ្រោះដោយសារប្រធានស័ក្តិ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរឃុំ-សង្កាត់ ឬស្ថាប័នមានសមត្ថកិច្ច ។ សម្រាប់គោលដៅនៃ ប្រកាសនេះ ពាក្យ «ប្រធានស័ក្ត» សំដៅដល់បាតុភូតធម្មជាតិ បាតុភូតនយោបាយ ឬបាតុភូតដទៃទៀតដែល បង្កឱ្យមានគ្រោះមហន្តរាយ

២- បំណុលពន្ធចុងក្រោយ មានអាយុកាលយ៉ាងតិច ៥ ឆ្នាំ ក្រោយការិយបរិច្ឆេទកត់ត្រាបំណុលពន្ធ

៣- អ្នកជាប់ពន្ធគ្មានលទ្ធភាពទូទាត់បំណុលពន្ធ ដោយមានការបញ្ជាក់ពីរដ្ឋបាលសារពើពន្ធនៅទីកន្លែង ។ ទោះបីជាបំណុលពន្ធ ត្រូវបានចាត់ទុកជាប្រាក់ពន្ធមិនអាចប្រមូលបានរួចក្តី រដ្ឋបាលសារពើពន្ធអាចអនុវត្តការទារបំណុលពន្ធនេះបានគ្រប់ពេលវេលា ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា បំណុលពន្ធអាចប្រមូលបានវិញ ។

ប្រការ២. សិទ្ធិសំរេចចាត់ទុកបំណុលជាប្រាក់ពន្ធមិនអាចប្រមូលបាន ជាសមត្ថកិច្ចរបស់:

១- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់តិចជាងឬស្មើនឹងដប់លានរៀល (១០,000,000 ៛)

២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់លើសពីដប់លានរៀល (១០,000,000 ៛) ។

ប្រការ៣. ដើម្បីចាត់ទុកបំណុលពន្ធជាប្រាក់មិនអាចប្រមូលបាន អគ្គនាយកដ្ឋានពន្ធដារត្រូវបង្កើតក្រុមការងារមួយដែលមានសមាសភាព និងភារកិច្ច ដូចខាងក្រោម:

១- សមាសភាពក្រុមការងារ:

- អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ.....................................................ជាប្រធាន
- ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុល.......................................ជាអនុប្រធាន
- ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬប្រធានសាខាពន្ធដារខេត្ត-ក្រុង-ខ័ណ្ឌ......ជាសមាជិក
- ប្រធានការិយាល័យបំណុលពន្ធនៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ.......ជាលេខាធិការ

២- ភារកិច្ចរបស់ក្រុមការងារ:

- ពិនិត្យនិងផ្ទៀងផ្ទាត់សំណើរសុំរបស់ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារ ខេត្ត-ក្រុង-ខ័ណ្ឌ ស្តីពីការចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន
- ចុះត្រួតពិនិត្យផ្ទាល់ដល់គ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងស្នាក់នៅរបស់អ្នកជាប់ពន្ធ ដែលជាកម្មវត្ថុនៃការស្នើសុំ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងលើកសំណើរជូនអគ្គនាយកនៃអគ្គនាយកដ្ឋាន ពន្ធដារ ឬនិង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសំរេច ។

ប្រការ៤. ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**គាត ឈន់**

<u>ចម្លងជូន</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង «ដើម្បីចម្លងជូន»
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «ដើម្បីមុខការ»
- គ្រប់អង្គភាពពន្ធដារ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ